ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០០៦៧ ព.ណ.ពក.គបប.ប្រក

# ប្រកាស
# ស្តីពី
# ខសន្យាមិនសុចរិត

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១._ គោលបំណង

ប្រកាសនេះ កំណត់អំពីលក្ខខណ្ឌនិងនីតិវិធី សម្រាប់អនុវត្តចំពោះទម្រង់ស្តង់ដានៃកិច្ចសន្យា និងប្រភេទខសន្យាមិនសុចរិត ដើម្បីការពារសិទ្ធិអ្នកប្រើប្រាស់ ពាក់ព័ន្ធនឹងអំពើកេងយកចំណេញហួសហេតុ និងការរំលោភបំពានលើស្ថានភាពដែលកើតមានឡើងតាមរយៈទំនាក់ទំនងនៃកិច្ចសន្យា ដែលធ្វើឡើងរវាងអ្នកប្រើប្រាស់និងបុគ្គលធ្វើធុរកិច្ច ដើម្បីផ្គត់ផ្គង់ទំនិញ និង/ឬសេវា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តលើគ្រប់ទម្រង់ស្តង់ដានៃកិច្ចសន្យា ដែលបង្កើតឡើងក្នុងគោលបំណងផ្គត់ផ្គង់ទំនិញនិង/ឬសេវា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចបានកំណត់ក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

**ប្រការ៣.- និយមន័យ**

វាក្យសព្ទសំខាន់ៗមួយចំនួននៃប្រកាសនេះ មានអត្ថន័យដូចខាងក្រោម៖

១. **បុគ្គលធ្វើធុរកិច្ច** សំដៅដល់បុគ្គលទាំងឡាយណាដែលធ្វើធុរកិច្ចដូចដែលបានកំណត់នៅក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

២. **ក្រមរដ្ឋប្បវេណី** សំដៅដល់ក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ និងការធ្វើវិសោធនកម្ម ឬការជំនួសក្រោយៗមកទៀត។

៣. **ខសន្យា** មានអត្ថន័យដូចដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

៤. **អ្នកប្រើប្រាស់** មានអត្ថន័យដូចដែលបានកំណត់នៅក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

៥. **ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក** មានអត្ថន័យដូចដែលបានកំណត់នៅក្នុងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

៦. **ទំនិញ** សំដៅដល់គ្រប់ចលនវត្ថុទាំងអស់ រួមបញ្ចូលទាំងវត្ថុរូបីនិងអរូបី លើកលែងតែរូបិយប័ណ្ណ និងអចលនវត្ថុ។

៧. **ទម្រង់ស្តង់ដានៃកិច្ចសន្យា** (Standard Form of Contract) សំដៅដល់កិច្ចសន្យា ឬខសន្យាណាមួយនៃកិច្ចសន្យា ដែលត្រូវបានរៀបចំជាមុនដោយបុគ្គលធ្វើធុរកិច្ចសម្រាប់ការផ្គត់ផ្គង់ទំនិញ និង/ឬសេវាទៅឱ្យអ្នកប្រើប្រាស់ ដោយមិនអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើការចរចា កែប្រែ ឬមានឥទ្ធិពលទៅលើខសន្យា ទោះក្នុងទម្រង់ណាមួយក៏ដោយ។

៨. **ខសន្យាសំខាន់ៗ** សំដៅដល់រាល់ខសន្យា ឬលក្ខខណ្ឌសំខាន់ៗណាមួយនៃកិច្ចសន្យា (ទោះក្នុងទម្រង់ស្តង់ដានៃកិច្ចសន្យាក្តី ឬទម្រង់ស្តង់ដាអេឡិចត្រូនិកក្តី) ដែលមានសារៈសំខាន់សម្រាប់អ្នកប្រើប្រាស់ ឬអ្នកប្រើប្រាស់យល់ថាមានសារៈសំខាន់ សម្រាប់ការបង្កើតកិច្ចសន្យា ហើយបុគ្គលធ្វើធុរកិច្ចគួរតែបានដឹងអំពីសារៈសំខាន់នៃលក្ខខណ្ឌ ឬខចែងនោះ។

៩. **ខសន្យាមិនសុចរិត** សំដៅដល់ខសន្យាណាមួយនៃទម្រង់ស្តង់ដានៃកិច្ចសន្យា ដែលបង្កើតឱ្យមាននូវការកេងយកចំណេញហួសហេតុពីអ្នកប្រើប្រាស់។

## ជំពូកទី២
## លក្ខខណ្ឌតម្រូវនៃទម្រង់ស្តង់ដានៃកិច្ចសន្យា

**ប្រការ៤.- លក្ខខណ្ឌតម្រូវនៃទម្រង់ស្តង់ដានៃកិច្ចសន្យា**

១. ទម្រង់ស្តង់ដានៃកិច្ចសន្យាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនិងច្បាស់លាស់ ដោយខសន្យានីមួយៗត្រូវប្រើពាក្យដែលងាយយល់។

២. ទម្រង់ស្តង់ដានៃកិច្ចសន្យាត្រូវធ្វើឡើងជាភាសាខ្មែរ។ បុគ្គលធ្វើធុរកិច្ចអាចបង្កើតទម្រង់ស្តង់ដានៃកិច្ចសន្យាជាភាសាបរទេស តាមការស្នើសុំរបស់អ្នកប្រើប្រាស់ បន្ថែមពីលើទម្រង់ស្តង់ដានៃកិច្ចសន្យាជាភាសាខ្មែរបាន។

១. រាល់ខសន្យាដែលលើកលែង ឬកម្រិតការទទួលខុសត្រូវរបស់បុគ្គលធ្វើធុរកិច្ចលើការធានាលើទំនិញ និង/ឬសេវាដូចមានកំណត់នៅក្នុង មាត្រា៥៣៩ មាត្រា៥៤០ មាត្រា៥៤១ មាត្រា៥៤២ មាត្រា៥៤៣ មាត្រា៥៤៤ និងមាត្រា៥៤៥ និងមាត្រាពាក់ព័ន្ធផ្សេងៗទៀតនៃក្រមរដ្ឋប្បវេណី។

២. រាល់ខសន្យាដែលផ្តល់សិទ្ធិឱ្យបុគ្គលធ្វើធុរកិច្ចក្នុងការកែប្រែ ឬផ្លាស់ប្តូរសំខាន់ៗទៅលើយថាប្រភេទ បរិមាណ តម្លៃ និងគុណភាពនៃទំនិញ និង/ឬសេវា ដោយមិនមានការយល់ព្រមជាមុនពីអ្នកប្រើប្រាស់។

៣. រាល់ខសន្យាដែលផ្តល់សិទ្ធិឱ្យបុគ្គលធ្វើធុរកិច្ច ក្នុងការកែប្រែខសន្យាសំខាន់ៗនៃទម្រង់ស្តង់ដានៃកិច្ចសន្យាដោយមិនមានការយល់ព្រមជាមុនពីអ្នកប្រើប្រាស់។

៤. រាល់ខសន្យាដែលផ្តល់សិទ្ធិឱ្យបុគ្គលធ្វើធុរកិច្ចក្នុងការបកស្រាយដោយឯកតោភាគី និងដោយដាច់ខាត ឬរំលាយកិច្ចសន្យាតាមឆន្ទានុសិទ្ធិរបស់បុគ្គលធ្វើធុរកិច្ច។

## ប្រការ១០._ ការកែប្រែខសន្យា

១. រាល់ការកែប្រែខសន្យាសំខាន់ៗ ត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអ្នកប្រើប្រាស់។

២. បុគ្គលធ្វើធុរកិច្ចត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅឱ្យអ្នកប្រើប្រាស់ មុនកាលបរិច្ឆេទសុពលភាព នៃរាល់ការកែប្រែខសន្យាទាំងឡាយណាដែលមិនមែនជាខសន្យាសំខាន់ៗ។

## ប្រការ១១._ សិទ្ធិអ្នកប្រើប្រាស់

អ្នកប្រើប្រាស់មានសិទ្ធិ៖

១. ទទួលបានព័ត៌មានសំខាន់ៗទាក់ទងនឹងទំនិញនិង/ឬសេវា និងខសន្យានៃទម្រង់ស្តង់ដានៃកិច្ចសន្យា។

២. ស្នើសុំឱ្យមានការស្រាយបំភ្លឺ និងពន្យល់បន្ថែមពីបុគ្គលធ្វើធុរកិច្ច និងទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីពិចារណាលើខសន្យា ជាពិសេសខសន្យាសំខាន់ៗ មុនពេលចុះហត្ថលេខា។

## ប្រការ១២._ បញ្ញត្តិករឬនិយ័តករមានសមត្ថកិច្ច

បញ្ញត្តិករឬនិយ័តករតាមវិស័យនីមួយៗ និងអាជ្ញាធរដែលមានសមត្ថកិច្ច អាចរៀបចំនូវលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីធ្វើការលម្អិតលើបញ្ហាដូចខាងក្រោម៖

១. សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកប្រើប្រាស់និងបុគ្គលធ្វើធុរកិច្ច ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវអប្បបរមាក្នុងការពន្យល់ និងនីតិវិធីនៃការចុះហត្ថលេខាលើទម្រង់ស្តង់ដានៃកិច្ចសន្យា និង

២. វិធានលម្អិត និងលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងខសន្យាមិនសុចរិត។

# ជំពូកទី៥
# ស្ថាប័នមានសមត្ថកិច្ច

## ប្រការ១៣._ ការត្រួតពិនិត្យបឋម

បុគ្គលធ្វើធុរកិច្ចត្រូវធានាថា ទម្រង់ស្តង់ដានៃកិច្ចសន្យាដែលបង្កើតឡើងដោយបុគ្គលធ្វើធុរកិច្ចនោះ ពុំមានចែងអំពីខសន្យាដែលមានការកេងយកចំណេញហួសហេតុ និងខសន្យាមិនសុចរិតនោះទេ។

ករណីបុគ្គលធ្វើធុរកិច្ចមានបំណងស្នើសុំឱ្យមានការត្រួតពិនិត្យលើទម្រង់ស្តង់ដានៃកិច្ចសន្យា ដើម្បីទទួលបានការបញ្ជាក់ពីអនុលោមភាព បុគ្គលធ្វើធុរកិច្ចអាចស្នើសុំឱ្យមានការត្រួតពិនិត្យទៅស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម៖

៣. ទម្រង់ស្តង់ដានៃកិច្ចសន្យាត្រូវកំណត់នូវព័ត៌មានអប្បបរមា ស្របតាមការតម្រូវដែលបានកំណត់ក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិជាធរមានផ្សេងៗ ដែលពាក់ព័ន្ធនឹងព័ត៌មានអប្បបរមានេះ។

**ប្រការ៥.- ការពន្យល់អំពីទម្រង់ស្តង់ដានៃកិច្ចសន្យា**

១. បុគ្គលធ្វើធុរកិច្ចត្រូវពន្យល់ បង្ហាញចំណុចសំខាន់ៗ និងផ្តល់ព័ត៌មានឱ្យច្បាស់លាស់អំពីខសន្យាសំខាន់ៗនៃទម្រង់ស្តង់ដានៃកិច្ចសន្យា។

២. ចំពោះពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អ្នកប្រើប្រាស់ត្រូវទទួលបានការពន្យល់ឱ្យបានច្បាស់លាស់អំពីខសន្យាសំខាន់ៗនៃទម្រង់ស្តង់ដានៃកិច្ចសន្យា ដើម្បីផ្តល់ឱកាសឱ្យអ្នកប្រើប្រាស់បានអានឱ្យបានច្បាស់លាស់ មុនពេលទទួលយកនូវទម្រង់ស្តង់ដានៃកិច្ចសន្យានោះ។

## ជំពូកទី៣
## អំពើកេងយកចំណេញហួសហេតុ

**ប្រការ៦.- អំពើកេងយកចំណេញហួសហេតុ**

បុគ្គលធ្វើធុរកិច្ចមិនត្រូវដាក់បញ្ចូលខសន្យាណាមួយ នៅក្នុងទម្រង់ស្តង់ដានៃកិច្ចសន្យា ដើម្បីកេងយកចំណេញហួសហេតុពីអ្នកប្រើប្រាស់ឡើយ ដូចបានកំណត់ក្នុងមាត្រា៣៥១នៃក្រមរដ្ឋប្បវេណី ។

**ប្រការ៧.- ការវិនិច្ឆ័យ និងការវាយតម្លៃអំពីអំពើកេងយកចំណេញហួសហេតុ**

១. ការវិនិច្ឆ័យនិងការវាយតម្លៃលើខសន្យាដែលមានលក្ខណៈកេងយកចំណេញហួសហេតុ ត្រូវធ្វើឡើងដោយពិចារណាគ្រប់ជ្រុងជ្រោយលើស្ថានភាពមួយឬទាំងឡាយ របស់ភាគីនៃទម្រង់ស្តង់ដានៃកិច្ចសន្យា ជាអាទិ៍ឧត្តមភាពផ្នែកសេដ្ឋកិច្ច ស្ថានភាពសង្គម ភាពល្ងង់ ឬការខ្វះបទពិសោធន៍ និងស្ថានភាពផ្សេងទៀតដែលមានសារៈសំខាន់ ឬនាំឱ្យមាននូវការបង្កើតកិច្ចសន្យា។

២. លក្ខខណ្ឌវិនិច្ឆ័យលើខសន្យាដែលមានលក្ខណៈកេងយកចំណេញហួសហេតុ អាចនឹងត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិតាមវិស័យនីមួយៗដែលចេញដោយក្រសួង ស្ថាប័ន បញ្ញត្តិករឬនិយ័តករមានសមត្ថកិច្ច។

## ជំពូកទី៤
## ខសន្យាមិនសុចរិត

**ប្រការ៨.- ការរំលោភបំពានលើស្ថានភាព**

បុគ្គលធ្វើធុរកិច្ចមិនត្រូវរំលោភបំពានលើស្ថានភាពដែលអ្នកប្រើប្រាស់មិនអាចធ្វើការកែប្រែនូវទម្រង់ស្តង់ដានៃកិច្ចសន្យាបាន ដោយធ្វើការកំណត់ខសន្យាមិនសុចរិតនៅក្នុងទម្រង់ស្តង់ដានៃកិច្ចសន្យា ដែលបង្កើតឱ្យមាននូវការកេងយកចំណេញហួសហេតុពីអ្នកប្រើប្រាស់នោះទេ។

**ប្រការ៩.- ខសន្យាដែលត្រូវចាត់ទុកជាខសន្យាមិនសុចរិត**

លើកលែងតែមានការកំណត់ជាក់លាក់នៅក្នុងបទប្បញ្ញត្តិតាមវិស័យនីមួយៗ បុគ្គលធ្វើធុរកិច្ចមិនត្រូវកំណត់ខសន្យាមិនសុចរិត ក្នុងទម្រង់ស្តង់ដានៃកិច្ចសន្យាដែលមានដូចខាងក្រោម៖



X

១. គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ សម្រាប់វិស័យណាដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់បញ្ញត្តិករឬនិយ័តករពិសេស ឬ

២. បញ្ញត្តិករឬនិយ័តករមានសមត្ថកិច្ចតាមវិស័យនីមួយៗ ស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

## ប្រការ១៤_ ការដាក់ពាក្យបណ្តឹង

អ្នកប្រើប្រាស់ឬភាគីពាក់ព័ន្ធណាមួយអាចដាក់ពាក្យបណ្តឹងដោយខ្លួនឯងផ្ទាល់ ឬតាមរយៈសមាគមអ្នកប្រើប្រាស់តាមវិស័យដែលពាក់ព័ន្ធ ចំពោះរាល់ការមិនអនុវត្តតាមប្រការណាមួយនៃប្រកាសនេះ ទៅស្ថាប័នមានសមត្ថកិច្ចដូចខាងក្រោម៖

១. គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ ឬ

២. ក្រសួង ស្ថាប័ន បញ្ញត្តិករឬនិយ័តករមានសមត្ថកិច្ចតាមវិស័យនីមួយៗស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ប្រការ១៥_ សមត្ថកិច្ចរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់

គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់មានឆន្ទានុសិទ្ធិក្នុងការផ្តួចផ្តើមការស៊ើបអង្កេតលើទម្រង់ស្តង់ដានៃកិច្ចសន្យាណាមួយរបស់បុគ្គលធ្វើធុរកិច្ច ដោយស្នើសុំឱ្យបុគ្គលធ្វើធុរកិច្ចនោះ ប្រគល់ ឬផ្តល់ឱ្យនូវទម្រង់ស្តង់ដានៃកិច្ចសន្យាដើម្បីត្រួតពិនិត្យ។

## ប្រការ១៦_ ការលុបចោល និងការផ្តល់សច្ចានុមតិ

អ្នកប្រើប្រាស់អាចលុបចោល ឬផ្តល់សច្ចានុមតិលើខសន្យាទាំងឡាយណាដែលមិនសុចរិត ឬមានលក្ខណៈកេងយកចំណេញហួសហេតុ ស្រមតាមលក្ខខណ្ឌតម្រូវនិងនីតិវិធីដែលបានកំណត់ក្នុង មាត្រា៣៦០ មាត្រា៣៦២ និងមាត្រា៣៦៣នៃក្រមរដ្ឋប្បវេណី ដោយចុះហត្ថលេខា ឬផ្តល់ស្នាមមេដៃលើទម្រង់លិខិតជាលាយលក្ខណ៍អក្សរដាច់ដោយឡែកពីទម្រង់ស្តង់ដានៃកិច្ចសន្យា ដែលបញ្ជាក់អំពីការផ្តល់សច្ចានុមតិ ឬលុបចោល។ រាល់ការលុបចោល ឬការផ្តល់សច្ចានុមតិរបស់អ្នកប្រើប្រាស់ ត្រូវលើកលែងតែការទទួលខុសត្រូវរបស់បុគ្គលធ្វើធុរកិច្ច ដែលមានកំណត់ក្នុងប្រកាសនេះ។

# ជំពូកទី៦
# អំពើនិងការអនុវត្តមិនសុចរិត និងការពិន័យអន្តរការណ៍

## ប្រការ១៧_ អំពើនិងការអនុវត្តមិនសុចរិត និងការពិន័យអន្តរការណ៍

រាល់ការប្រើប្រាស់ខសន្យាមិនសុចរិត ដែលត្រូវបានហាមឃាត់ដោយប្រកាសនេះ ត្រូវចាត់ទុកថាជាអំពើមិនសុចរិត និងការអនុវត្តមិនសុចរិតដែលស្ថិតនៅក្រោមច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

បុគ្គលធ្វើធុរកិច្ចណាមួយដែលបានរំលោភបំពានលើបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ ស្របតាមមាត្រា៤១ និងមាត្រា៤៤នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

រាល់ការពិន័យអន្តរកាណ៍ដែលបានកំណត់ក្នុងប្រកាសនេះមិនត្រូវលើកលែងការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ដែលមានកំណត់នៅក្នុងច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដទៃទៀតនោះទេ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

### ប្រការ១៨._ និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ១៩._ ការអនុវត្ត

សមាសភាពនៃគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធត្រូវទទួលខុសត្រូវលើការអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ក្នុងរយៈពេល ៦ខែចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ.អង្គារ ១៤រោច ខែ.មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី...១... ខែ.មីនា.. ឆ្នាំ.២០២២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ